# ពង្រឹងភាពជាម្ចាស់របស់ពលរដ្ឋ

## ដើម្បីរៀបចំផែនការ និងផ្តល់សេវា សម្រាប់ទាំងអស់គ្នា!



៤ មិថុនា ២០២៦ – ៣១ សីហា ២០២៨

©Nim Sreyroth/SILAKA

## បរិបទ

ប្រទេសកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការធ្វើវិមជ្ឈការ និងកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន។ ទោះបីជាយ៉ាងនេះក៏ដោយ ការសម្រេចចិត្តផ្នែកថវិកាភាគច្រើនធ្វើឡើងនៅថ្នាក់ជាតិ ហើយក្រុមងាយរងគ្រោះជាច្រើនទៀតនៅតែជួបប្រទះបញ្ហាប្រឈមក្នុងការចូលរួម និងមានឥទ្ធិពលលើការសម្រេចចិត្តក្នុងការរៀបចំផែនការ និងការចំណាយសាធារណៈនៅមូលដ្ឋាន។ ប្រជាពលរដ្ឋជាច្រើននៅពុំទាន់មានលទ្ធភាពទទួលបានព័ត៌មានថវិកា ដែលមានលក្ខណៈងាយស្រួលយល់ ខណៈដែលសមត្ថភាពអាជ្ញាធរមូលដ្ឋាននៅមានកម្រិតក្នុងការសម្របសម្រួលការចូលរួមពេញលេញពីប្រជាពលរដ្ឋ។

គម្រោង **ពង្រឹងភាពជាម្ចាស់របស់ពលរដ្ឋ ដើម្បីរៀបចំផែនការ និងផ្តល់សេវាសម្រាប់ទាំងអស់គ្នា** ឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ តាមរយៈការពង្រឹងចំណេះដឹង និងសមត្ថភាពរបស់អាជ្ញាធរ និងរដ្ឋបាលថ្នាក់មូលដ្ឋាន ព្រមទាំងការបង្កើនការយល់ដឹងរបស់សហគមន៍អំពីការគ្រប់គ្រងថវិកាសាធារណៈនៅថ្នាក់ក្រោមជាតិ។ គម្រោងក៏បានជួយពង្រឹងវេទិកាសម្រាប់កិច្ចសន្ទនា និងកិច្ចសហការនៅថ្នាក់មូលដ្ឋាន ដើម្បីលើកកម្ពស់តម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដោយធានាថា អាទិភាព និងតម្រូវការរបស់មូលដ្ឋានត្រូវបានឆ្លុះបញ្ចាំងក្នុងការរៀបចំផែនការ ការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ។

## ដៃគូអនុវត្តគម្រោង

- វិទ្យាស្ថានតស៊ូមតិ និគោលនយោបាយ
- សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
- អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព
- វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
- អង្គការសីលការ
- អង្គការកម្មវិធីអភិវឌ្ឍធនធានយុវជន



## ដៃគូយុទ្ធសាស្ត្រ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងអប់រំ យុវជន និងកីឡា
- លេខាធិការដ្ឋាន គណៈកម្មាធិការជាតិគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- សាលាជាតិរដ្ឋបាលមូលដ្ឋាន
- សមាជិកក្រុមប្រឹក្សាខេត្ត ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ជំនួយការហិរញ្ញវត្ថុឃុំ និងស្មៀន
- ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន
- ស្ថាប័នសិក្សា/ស្ថាប័នស្រាវជ្រាវ
- អង្គការសង្គមស៊ីវិល និងអង្គការសហគមន៍មូលដ្ឋាន


**អង្គការអុកស្វាមប្រចាំកម្ពុជា**

អគារ The Point ជាន់ទី 3 លេខ 113C មហាវិថីម៉ៅសេទុង
សង្កាត់ទួលស្វាយព្រៃទី 1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

+855 23 885 412 / +855 23885413
Info.Cambodia@oxfam.org
@OxfaminCambodia
@Oxfamkh

CAMBODIA.OXFAM.ORG



គាំទ្រដោយ

Swiss Agency for Development and Cooperation SDC

អនុវត្តដោយ

OXFAM

## គោលបំណង

ប្រជាពលរដ្ឋចូលរួម និងផ្តល់មតិយោបល់ក្នុងដំណើរការគ្រប់គ្រងថវិកាថ្នាក់ក្រោមជាតិ ដើម្បីរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការឆ្លើយតបកាន់តែប្រសើរឡើងក្នុងការបែងចែកធនធានសាធារណៈ និងការផ្តល់សេវាសាធារណៈ។



## វិធីសាស្រ្តអនុវត្ត

- ពង្រឹងសមត្ថភាព និងការគាំទ្រដល់អាជ្ញាធរថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន ក្រុមយុវជន ក្រុមស្ត្រី ក្រុមងាយរងគ្រោះ ជនមានពិការភាព និងអ្នកសារព័ត៌មានទាក់ទងការគ្រប់គ្រងថវិកាថ្នាក់ក្រោមជាតិ ការចូលរួមរបស់ពលរដ្ឋ ការប្រើប្រាស់កម្មវិធីទាក់ទងថវិកា និងសេវាថ្នាក់ក្រោមជាតិ និងការស្រាវជ្រាវបែបសកម្ម។
- គាំទ្រដល់គំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋក្នុងការវិភាគថវិកា ការតាមដានលទ្ធកម្មសាធារណៈ និងការសិក្សាស្រាវជ្រាវបែបសកម្ម។
- គាំទ្រសហគមន៍ក្នុងការរួមបញ្ចូលសកម្មភាពចូលទៅក្នុងផែនការសហគមន៍។
- គាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការ និងការតាមដានថវិកា (ផែនការប្រចាំឆ្នាំ ផែនការសកម្មភាពពាឆ្នាំរំកិល ផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍៥ឆ្នាំ)។
- គាំទ្រយន្តការចូលរួមពីពហុភាគីពាក់ព័ន្ធ ដោយផ្សារភ្ជាប់កិច្ចសន្ទនាគោលនយោបាយពីថ្នាក់មូលដ្ឋាន ទៅថ្នាក់ជាតិ។

## លទ្ធផលគម្រោង

**លទ្ធផលទី១**

### ការពង្រឹងសមត្ថភាព និងការចូលរួម

ពង្រឹងសមត្ថភាពពលរដ្ឋ និងរដ្ឋបាលមូលដ្ឋានថ្នាក់ក្រោមជាតិក្នុងការយល់ដឹង ទទួលបាន និងប្រើប្រាស់ព័ត៌មានថវិកា និងឧបករណ៍ឌីជីថលសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការរៀបចំផែនការថវិកា និងការសម្រេចចិត្តផ្អែកថវិកានៅមូលដ្ឋាន។

**លទ្ធផលទី២**

### តម្លាភាព គណនេយ្យភាព និងការតាមដាន

លើកកម្ពស់យន្តការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការតាមដាន និងយន្តការគណនេយ្យភាពសម្រាប់ការចំណាយសាធារណៈនៅថ្នាក់មូលដ្ឋានដើម្បីគាំទ្រដល់តម្លាភាព និងការឆ្លើយតបកាន់តែប្រសើរចំពោះអាទិភាពរបស់សហគមន៍។

**លទ្ធផលទី៣**

### ការពង្រឹងយន្តការស្ថាប័ន និងនិរន្តរភាព

លើកកម្ពស់យន្តការរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន តម្លាភាព និងយន្តការឆ្លើយតបដែលធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋទៀងទាត់ក្នុងការរៀបចំផែនការសកម្មភាពថវិកា និងការតាមដានសេវាសាធារណៈនៅមូលដ្ឋាន។

## លទ្ធផលសំខាន់ៗ

ប្រជាពលរដ្ឋមូលដ្ឋានទទួលបានចំណេះដឹង និងជំនាញស្តីពីការគ្រប់គ្រងថវិកានៅមូលដ្ឋាន ការតាមដានថវិកា ការសិក្សាស្រាវជ្រាវបែបសកម្ម និងការស្វែងរកមតិគាំទ្រតាមរយៈការចូលរួមជាមួយអាជ្ញាធរឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ ខេត្ត/រាជធានី និងនៅថ្នាក់ជាតិលើការធ្វើវិមជ្ឈការថវិកា។

ក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្រុក ក្រុ/ខណ្ឌទទួលបានចំណេះដឹងក្នុងការប្រើប្រាស់កម្មវិធីទាក់ទងថវិកា និងសេវាថ្នាក់ក្រោមជាតិតាមប្រព័ន្ធអនឡាញ និងសមត្ថភាពស្តីពីការរៀបចំនិងការគ្រប់គ្រងថវិកាថ្នាក់ក្រោមជាតិតាមបែបចូលរួម។

ប្រជាពលរដ្ឋទទួលបានព័ត៌មានថវិកានៅថ្នាក់ក្រោមជាតិ និងការផ្តល់សេវាសាធារណៈតាមរយៈថ្នាលឌីជីថលអនឡាញរួមមាន គេហទំព័រ កម្មវិធីតាមទូរស័ព្ទ ហ្វេសបុក តេឡេក្រាម និងដោយផ្ទាល់តាមវេទិកាសហគមន៍។

ក្រុមគោលដៅ រួមមានយុវជន ស្ត្រី និងអង្គការសហគមន៍មូលដ្ឋានមានសមត្ថភាពផ្តួចផ្តើមសកម្មភាពនានាស្តីពីវិមជ្ឈការថវិកា ថវិកាឆ្លើយតបនឹងយេនឌ័រ ការតាមដានថវិកា និងគណនេយ្យភាព។

សាលារៀនគោលដៅ និងអង្គការសហគមន៍មូលដ្ឋានបញ្ចូលសកម្មភាពការចូលរួមរបស់ពលរដ្ឋទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំនិងអនុវត្តសកម្មភាពក្នុងសហគមន៍។

ក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្រុក/ក្រុង/ខណ្ឌ បានអនុវត្ត និងពង្រឹងគោលនយោបាយ គោលការណ៍ណែនាំ និងយន្តការស្តីពីការចូលរួមរបស់ ពលរដ្ឋក្នុងការគ្រប់គ្រងថវិកា ការរៀបចំផែនការដោយមានការចូលរួម និងគណនេយ្យភាព។

## ក្រុមគោលដៅ

**៦០**ឃុំ **១៤**ស្រុក **៦**ខេត្តក្រុង




**អ្នកទទួលផលផ្ទាល់ និងប្រយោល**

**៤០០,០០០នាក់**

**អ្នកទទួលផលផ្ទាល់**

សមាជិកសហគមន៍

**៥,០០០នាក់**

- យុវជនប្រមាណ ១,២០០ នាក់
- ៤៧០ ឃុំ អង្គការសង្គមស៊ីវិល បណ្តាញមូលដ្ឋាន សមាជិកក្រុមប្រឹក្សាស្រុក/ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ